ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ទូរស័ព្ទ/ទូរសារ : ៨៥៥-០២៣-៩៧២២៧៩៥

~ ~ ~ ~ ~

លេខ : ០១៣ ប្រក.សហវ.គរ

~ ~ ~ ~ ~ ~ ~ ~ ~

រាជធានីភ្នំពេញ , ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៩៨

# ប្រកាស
## ស្តីពី
## និតិវិធីក្នុងការនាំចេញ-នាំចូលរូបិយប័ណ្ណបរទេស

~ ~ ~ ~ ~

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ,
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ,
- បានឃើញព្រះរាជក្រឹត្យ នស.រកត១០៩៤.៨៣ ចុះថ្ងៃទី២៤ខែតុលាឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល ,
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ,
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម នស.រកម.០១៩៦/១៨ ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ,
- បានឃើញព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ខែសីហាឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល ,
- បានឃើញច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ជស/រកម/០៨៩៧/០៣ ចុះថ្ងៃទី២២ខែសីហាឆ្នាំ១៩៩៧ ,

- បានឃើញលិខិតរបស់ទីស្ដីការគណៈរដ្ឋមន្ត្រីលេខ៤៦សជណ.សរ ចុះថ្ងៃទី១៥ ខែមករាឆ្នាំ១៩៩៨
- យោងតម្រូវការចាំបាច់របស់ក្រសួង ។

<u>សំរេច</u>

<u>ប្រការ១</u> : ការនាំចូលនូវរូបិយប័ណ្ណបរទេសមកក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដោយគណៈប្រតិភូនានា ភ្ញៀវគ្រប់ប្រភេទ និតិបុគ្គល និង រូបវ័ន្តបុគ្គលដទៃទៀត ហៅកាត់ថា " អ្នកដំណើរ " ពុំមានការកំរិតបរិមាណទេ ។

អ្នកដំណើរដែលនាំចូលនូវរូបិយប័ណ្ណបរទេសមានទឹកប្រាក់ស្មើ ឬ លើសពី ១០.០០០ " មួយម៉ឺន " ដុល្លារអាមេរិក ចាំបាច់ត្រូវបំពេញប្រតិវេទន៍គយនិងរដ្ឋាករ តាមនិតិវិធីកំណត់ជាធរមាន ហើយ ត្រូវប្រគល់ឱ្យមន្ត្រី-ភ្នាក់ងារគយនិងរដ្ឋាករ សំរាប់ពិនិត្យផ្ទៀងផ្ទាត់នៅពេលនាំចេញទៅវិញ ។

<u>ប្រការ២</u> : អ្នកដំណើរដែលនាំចេញនូវរូបិយប័ណ្ណបរទេសពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា មានទឹកប្រាក់លើសពី ១០.០០០ " មួយម៉ឺន " ដុល្លារអាមេរិក ឬ លើសពីចំនួនរូបិយប័ណ្ណបរទេសដែលសាមីខ្លួនបានប្រកាសក្នុងប្រតិវេទន៍គយនិងរដ្ឋាករនាពេលនាំចូល ត្រូវមានការអនុញ្ញាតឱ្យនាំចេញពីធនាគារជាតិនៃកម្ពុជា និង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានា ។

<u>ប្រការ៣</u> : អ្នកដំណើរដែលនាំចេញរូបិយប័ណ្ណបរទេសដូចមានចែងក្នុងប្រការ២ខាងលើ ត្រូវអនុវត្តដូចតទៅ :

- បង្ហាញចំពោះមន្ត្រី-ភ្នាក់ងារគយនិងរដ្ឋារនូវលិខិតអនុញ្ញាតឱ្យនាំចេញដែលផ្ដល់ដោយធនាគារជាតិនៃកម្ពុជា .
- បំពេញប្រតិវេទន៍គយនិងរដ្ឋាករឱ្យបានត្រឹមត្រូវ គ្រប់គ្រាន់ និង ច្បាស់លាស់ .
- ធ្វើដំណើរតាមមាត់ច្រកចូល-ចេញដែលបានកំណត់ដោយ ភ្នាក់ងារមានសមត្ថកិច្ច ។ ការយករូបិយប័ណ្ណធ្វើដំណើរតាមច្រកផ្លូវផ្សេង ឬ ដោយអ្នកកាន់បញ្ញើដទៃ ក្រៅពីម្ចាស់កម្មសិទ្ធិ ត្រូវបានហាមឃាត់ជាដាច់ខាត ។
- បំពេញជាលាយល័ក្ខអក្សរឱ្យបានត្រឹមត្រូវ គ្រប់គ្រាន់និង ច្បាស់លាស់លើប្រតិវេទន៍គយនិងរដ្ឋាករ អំពីប្រភេទ និង ចំនួនរូបិយប័ណ្ណដែលមានជាប់នឹងខ្លួន បញ្ញើជាមួយអ្នកដទៃ បញ្ញើតាមយន្តហោះ ដើម្បី

បង្ហាញដល់មន្ត្រី-ភ្នាក់ងារគយនិងរដ្ឋាករដែលមាន ភារកិច្ចត្រួតពិនិត្យនៅក្នុងការិយាល័យគយនិងរដ្ឋាករ ។

ប្រការ៤ : មន្ត្រី-ភ្នាក់ងារគយនិងរដ្ឋាករ ដែលបំពេញភារកិច្ចនៅតាមមាត់ច្រកនាំចេញ-នាំចូល ត្រូវអនុវត្ត ដូចតទៅ :

- ទទួល និង ពិនិត្យលើប្រតិវេទន៍គយនិងរដ្ឋាករព្រមទាំង ឯកសារភ្ជាប់ចាំបាច់ផ្សេងៗទៀតរបស់អ្នកដំណើរដែលនាំចេញរូបិយប័ណ្ណបរទេស.
- ធ្វើការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ជាមួយប្រតិវេទន៍គយនិងរដ្ឋាករ របស់អ្នកដំណើរដែលបានបំពេញនាពេលនាំចូល និង អ្នកដំណើរដែលនាំចេញរូបិយប័ណ្ណបរទេសនូវប្រភេទ និង ចំនួនសាច់ប្រាក់ដែលត្រូវនាំចេញជាក់ស្តែង ។

ប្រការ៥ : រាល់សកម្មភាពល្មើសដែលបង្កឡើងដោយអ្នកដំណើរដែលនាំចូល និង / ឬ នាំចេញរូបិយប័ណ្ណបរទេស ទោះជាតាមរូបភាពណាក្តី ( មិនរាយការណ៍ រាយការណ៍មិនត្រឹមត្រូវ ចេញខុសតម្រាយផ្លូវកំណត់ ឬ រូបភាពល្មើសផ្សេងៗទៀត ) ដែលមន្ត្រី-ភ្នាក់ងារគយនិងរដ្ឋាកររកឃើញ ត្រូវធ្វើកំណត់ហេតុ ឃាត់ទុក និង ទទួលរងនូវការវិនិច្ឆ័យទោសតាមច្បាប់កំណត់ជាធរមាន ។

ប្រការ៦ : មន្ត្រី-ភ្នាក់ងារគយនិងរដ្ឋាករដែលបានចូលរួមប្រព្រឹត្តសកម្មភាពល្មើស ឬ ប្រព្រឹត្តខុសពីប្រកាសនេះ ត្រូវទទួលទោសទណ្ឌតាមច្បាប់ស្តីពីសហលក្ខន្តិកៈនៃមន្ត្រី រាជការស៊ីវិល និង សារាចរលេខ០០១សរ.សហវ.គរ ចុះថ្ងៃទី០៦ខែមករាឆ្នាំ១៩៩៥ ស្តីពីការគ្រប់គ្រងមន្ត្រីរាជការគយនិងរដ្ឋាករ ។

ប្រការ៧ : អគ្គនាយក នាយកខុទ្ទកាល័យ ប្រធានមន្ទីរ នាយកទីចាត់ការគយនិងរដ្ឋាករ និង អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងមហាផ្ទៃ
- ទីចាត់ការគយនិងរដ្ឋាករ " ដើម្បីអនុវត្ត "
- ឯកសារ កាលប្បវត្តិ

គាត ឈន់